៥-លោកជំទាវ ជី សុគី ទឹកប្រាក់ ១០.១០០ USD

៦-លោក ប្រួក សារឿន ទឹកប្រាក់ ២១.៥៥៦ USD

៧-លោកជំទាវ ខី សារ៉ុន ទឹកប្រាក់ ១២.៦៥៦,២៨USD

៨-លោកវរសេនីយ៍ឯក មុំ សំ ទឹកប្រាក់ ១២.២៨០ USD

៩-លោក ព្រុំ ណៃ ទឹកប្រាក់ ១១.៥៣០ USD

១០-លោក មោក សុធារិន ទឹកប្រាក់ ២៨.៩២២ USD

១១-លោកស្រី យូ លីម ទឹកប្រាក់ ១៣.០៥២ USD

១២-លោកស្រី មុីន ស៊ីថា ទឹកប្រាក់ ២៦.៣០០ USD

១៣-លោកឧកញ៉ា ប៉ាន់ ពៅ ទឹកប្រាក់ ១៨.០០០ USD

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

-លោក វរសេនីយ៍ត្រី វេជ្ជបណ្ឌិត ហឿង តិរឿន

និងអ្នកស្រី ឈុន ដាវ៉ាន់ ទឹកប្រាក់ ៦.៣៣០ USD

គ-មេដាយសំរិទ្ធស្ថាបនាជាតិ :

-លោក វរសេនីយ៍ឯក ពៅ លីមមី ទឹកប្រាក់ ៨.៥០០ USD

មាត្រា ២ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

★ ★ ★

## ២-សារាចរ

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៩៨

### សារាចរលេខ ០១ ស.រ

### ស្តីពីការចាត់តាំងរៀបចំពិធីបុណ្យចំរើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគម្រប់ព្រះជន្ម ៧៦ យាងចូល ៧៧ ព្រះវស្សា បុណ្យខួបអនុស្សាវរីយ៍លើកទី ៤៥ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក

****

★ ពិធីបុណ្យចំរើនព្រះជន្មព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈ ក្នុងគម្រប់ព្រះជន្ម ៧៦ យាងចូល ៧៧ ព្រះវស្សា នឹងត្រូវប្រព្រឹត្តទៅចំនួន ៣ថ្ងៃ ចាប់ពីថ្ងៃទី ៣០-៣១ តុលា ដល់ថ្ងៃ ០១ វិច្ឆិកា ១៩៩៨ ខាងមុខនេះ ដើម្បីសំដែងកតញ្ញូតាធម៌ចំពោះព្រះមហាករុណាទិគុណ ថ្វាយព្រះពរសព្ទសាធុការ និង ថ្វាយមហាកុសលចំពោះ

**ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ទ្រង់មានព្រះជន្មាយុយឺនយូរ ព្រះសុខអាយុភាពល្អបរិបូណ៌ ព្រះកាយពលរឹងមាំ និងព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់របស់ប្រជារាស្ត្រខ្មែរយូរអង្វែងតរៀងទៅ ។

★ ពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៤៥ នៃទិវាបុណ្យឯករាជ្យជាតិ នឹងត្រូវប្រព្រឹត្តទៅនៅថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ដើម្បីសំដែងមនោសញ្ចេតនាអបអរសាទរ រំលឹកទិវាជាប្រវត្តិសាស្ត្រ ដែលកំលាំងមហាសាមគ្គីជាតិទាំងមូល បានធ្វើអោយបានទាំងស្រុងមកវិញពីអាណានិគមនិយមបារាំង នាឆ្នាំ ១៩៥៣ នូវឯករាជ្យជាតិដ៏ពិតប្រាកដ ក្រោមព្រះរាជបូជនីយកិច្ចដ៏ថ្លៃថ្លា នៃព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

★ ពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និង អកអំបុក នឹងត្រូវប្រព្រឹត្តទៅចំនួន ៣ថ្ងៃ គឺថ្ងៃ ១៤-១៥ កើត និងថ្ងៃ ១ រោច ខែ កត្តិក ត្រូវនឹងថ្ងៃទី ២-៣-៤ វិច្ឆិកា ១៩៩៨ ដើម្បីបើកឱកាសជូនប្រជារាស្ត្រសប្បាយរីករាយ ចូលរួមថែរក្សានូវប្រពៃណីរបស់ជាតិ ដែលជាប់ទាក់ទងទៅនឹងប្រវត្តិពិធីសមយុទ្ធនៃកំលាំងសាមគ្គីកងទ័ពជើងទឹករបស់យើង ក្នុងបុព្វហេតុការពារមាតុភូមិ និង សំដែងមនោសញ្ចេតនា ប្រកបដោយកតញ្ញូតាធម៌ចំពោះមហាករុណាទិគុណនៃព្រះរតនត្រ័យ ពពួកទេវតា និងវត្ថុសក្តិសិទ្ធិ ដែលបានថែរក្សា និង ផ្តល់ផលទុំបរិបូណ៌អោយវិស័យកសិកម្មជាតិ មានការចំរើនរុងរឿង ព្រមទាំងជាឱកាសបួងសួងសុំអោយបារមី នៃព្រះពុទ្ធជាម្ចាស់ និងវត្ថុសក្តិសិទ្ធិទាំងនោះ បន្តផ្តល់ផលទុំបរិបូណ៌អោយវិស័យកសិកម្មនាឆ្នាំខាងមុខអោយទទួលបានជោគជ័យ និងទិន្នផលខ្ពស់ជាងនេះថែមទៀត ។

ដើម្បីចាត់តាំងរៀបចំពិធីបុណ្យទាំងបីនេះ អោយបានសមរម្យ សក្តិសមទៅនឹងអត្ថន័យដ៏ជ្រាលជ្រៅដូចបានបញ្ជាក់ខាងលើនេះ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមដាក់ចេញសារាចរដូចតទៅនេះ :

**១-អំពីបុណ្យចំរើនព្រះជន្មវស្សា :**

-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ សហការជាមួយក្រសួងព្រះបរមរាជវាំង ត្រូវចាត់តាំងពិធីបុណ្យចំរើនព្រះជន្មព្រះករុណាជាម្ចាស់ជីវិតលើត្បូង ស្របតាមប្រពៃណីជាតិនិងប្រពៃណីសាសនាដោយមានថ្នាក់ដឹកនាំ រដ្ឋសភា រដ្ឋាភិបាល ព្រះរាជវង្សានុវង្ស ចូលរួមថ្វាយព្រះពរ ។

-គ្រប់ខេត្ត-ក្រុង ត្រូវចាត់តាំងរៀបចំពិធីបុណ្យចំរើនព្រះជន្មព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ក្នុងក្របខ័ណ្ឌ ខេត្ត-ក្រុង របស់ខ្លួនដោយមានរៀបចំសារថ្វាយព្រះពរ ។

-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត-ក្រុង ត្រូវរៀបចំតាំងព្រះឆាយាលក្ខណ៍ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង តុបតែងលំអរចនាដោយភ្លើងពណ៌ និងពាក្យស្លោកថ្វាយព្រះពរ ។

**២-អំពីពិធីបុណ្យឯករាជ្យជាតិ :**

-ត្រូវចាត់តាំងរៀបចំពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៤៥ នៃទិវាឯករាជ្យជាតិ ៩ វិច្ឆិកា ក្នុងតម្រិតរូបភាពមួយដ៏មហោឡារិក សក្តិសមទៅនឹងកិត្តិយសប្រទេសជាតិ ដោយមានចាត់តាំងមិទ្ទិញមហាជនមួយ នៅបរិវេណវិមានឯករាជ្យ មានថ្នាក់ដឹកនាំជាតិ មន្ត្រីរាជការ ប្រជាពលរដ្ឋ និងភ្ញៀវអន្តរជាតិចូលរួមអោយបានច្រើនកុះករ មានសុន្ទរកថាថ្នាក់ដឹកនាំជាន់ខ្ពស់ មានប្រវត្តិព្រះរាជបូជនីយកិច្ចទាមទារ

ឯករាជ្យ ម្នានចំណោមអារម្មណ៍របស់ព័ណែក អង្គមិទ្ធិញ មានតាំងពិព័រណ៍រូបភាពស្តីពីសមិទ្ធផលរបស់រាជរដ្ឋាភិបាលក្នុងរយៈពេល ៥ឆ្នាំ ដោយមានបោះពុម្ពសៀវភៅរូបថត អាហ្វិស ប៉ាណូ ផ្សព្វផ្សាយ ប្លូកាយផង និងមានចាត់តាំងពិធីដុតទៀនជ័យដាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធ និងពន្លត់ទៀនជ័យនៅវិមានឯករាជ្យ ព្រមទាំងមានបង្ហោះប៉េងប៉ោង លែងព្រាបជានិមិត្តរូប នៃការសុំសុខសន្តិភាពផង ។ កម្មវិធីលំអិត អាស្រ័យលើគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិអន្តរជាតិជាអ្នករៀបចំ ។

-ខេត្ត-ក្រុង ត្រូវចាត់តាំងពិធីមិទ្ទិញអបអរជន និង ពិធីគោរពវិញ្ញាណក្ខន្ធនៅតាមទីកន្លែងដ៏សមគួរតាមការជាក់ស្តែងរបស់ខេត្ត-ក្រុង នីមួយៗ ។

-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ ត្រូវរៀបចំកម្មវិធីសំរាប់ថ្នាក់ដឹកនាំក្រសួងរដ្ឋលេខាធិការដ្ឋាន ស្ថាប័នចុះសួរសុខទុក្ខយុទ្ធជនរបួស មានជម្ងឺកំពុងសំរាកព្យាបាលនៅតាមមន្ទីរពេទ្យ យុទ្ធជនពិការ នៅតាមមណ្ឌលយុទ្ធជនពិការ កុមារកំព្រា នៅតាមមណ្ឌលកុមារកំព្រា ដោយមាននាំអំណោយជួយឧបត្ថម្ភ និងបំផុសអោយគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ចងបដា ពាក្យស្លោក ដោតទង់ជាតិ ទង់ភ្លែប និងតុបតែង លំអភ្លើងពណ៌អោយបានឧឡារិក ។

**៣-អំពីពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក :**

-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ សហការជាមួយក្រសួងពាក់ព័ន្ធ និងខេត្ត -ក្រុង ចាត់តាំងរៀបចំពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក នៅតាមដងទន្លេសាបនៅវេទិកាអុំទូកមុខព្រះបរមរាជវាំងក្នុងរយៈពេល ៣ថ្ងៃ តាមប្រពៃណីជាតិ ប្រពៃណីសាសនា ដោយមានចាត់តាំងក្រសួងមួយចំនួន រចនាតុបតែងជាប្រទីប មានអុចកាំជ្រួចភ្លឺទៀន មានតាំងភ្លើងពណ៌រៀងរាល់យប់នៅរាជធានីភ្នំពេញ ។

-ត្រូវមានផែនការណែនាំលំអិតជាក់ស្តែង ស្តីពីលក្ខខណ្ឌទាំងឡាយនៃការជ្រើសរើសទូក ង ដែលត្រូវចូលរួមប្រណាំង ដោយត្រូវកំណត់ទូកអុំ ទូកចែវ អោយបានច្បាស់លាស់ និងត្រូវធ្វើសេចក្តីអំពាវនាវសប្បុរសជន បណ្តាក្រុមហ៊ុនឯកជន អោយជួយឧបត្ថម្ភជាសំភារៈ ថវិកា សំរាប់ជូនរង្វាន់ដល់កីឡាករអុំទូក ។

-ត្រូវប្លូកសរុបតំរោងថវិកាចំណាយលំអិតដែលក្រសួងពាក់ព័ន្ធបានលើកឡើង ក្នុងស្មារតីសន្សំសំចៃ ថ្លៃប្រឹតខ្ពស់ ផ្ញើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និង សំរេច ។

-ខេត្ត-ក្រុង ដែលមានទូក ង ចូលរួមប្រណាំង ត្រូវធ្វើការសាកល្បងហ្វឹកហាត់ ចម្រាញ់ជ្រើសរើសទូកដែលមានចំណាត់ថ្នាក់ជាទូកលឿនរបស់ខេត្ត-ក្រុង ក្នុងចំនួនសមស្រប សំរាប់ចូលរួមប្រណាំងនៅរាជធានីភ្នំពេញ ។

-ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវចាត់តាំងរៀបចំកម្មវិធីសិល្បៈ និងចំរៀងសម័យ បុរាណសំដែងជូនប្រជារាស្ត្រទស្សនាកំសាន្តនៅតាមទីសាធារណៈ អបអរសាទរក្នុងពិធីបុណ្យទាំងបីខាងលើ ។ ខេត្ត-ក្រុង ក៏ត្រូវមានចាត់តាំងសិល្បៈសំដែងជូនប្រជារាស្ត្រទស្សនាកំសាន្ត តាមលទ្ធផលភាពជាក់ស្តែងរបស់ខ្លួន ។

-ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវត្រៀមលក្ខណៈដោះស្រាយសំភារៈ និងថវិកាសំរាប់បំរើការរៀបចំពិធីបុណ្យទាំងបីខាងលើ អោយបានសមស្រប និងទាន់ពេលវេលា ។

-ក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិ ត្រូវត្រៀមលក្ខណៈចាត់តាំងការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរ តាមសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាសុវត្ថិភាព និងសេចក្តីសប្បាយរីករាយជូនប្រជាពលរដ្ឋយើង ។

ទទួលបានសារាចរនេះ សូមឯកឧត្តមរដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ស្ថាប័នពាក់ព័ន្ធ និង អភិបាលខេត្ត-ក្រុង ចាត់តាំងអនុវត្តអោយបានសំរេចលទ្ធផលល្អប្រសើរ ស្របតាមគោលបំណង និងសំណូមពរ ហើយធ្វើរបាយការណ៍ប្អូកសរុបជូនរាជរដ្ឋាភិបាល ។

ជ.រាជរដ្ឋាភិបាល

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

★ ★ ★

## ពាក្យស្លោកសម្រាប់ប្រើប្រាស់
## ក្នុងពិធីបុណ្យចំរើនព្រះជន្ម ព្រះមហាក្សត្រ
## បុណ្យឯករាជ្យជាតិ និង បុណ្យអុំទូក ឆ្នាំ ១៩៩៨

****

១- សូមថ្វាយព្រះពរព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា មានព្រះសុខមាលភាពល្អបរិបូណ៌ និងព្រះជន្មាយុយឺនយូរ ។

២- សូមថ្វាយព្រះពរសម្តេចឪ និងសម្តេចម៉ែ សូមមានព្រះជន្មាយុយឺនយូរ ។

៣- ជយោ ! សម្តេចឪ និងសម្តេចម៉ែ

៤- អបអរសាទរយ៉ាងក្លៀវក្លា ខួបអនុស្សាវរីយ៍លើកទី ៤៥ ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា " ០៩-១១-៥៣- ០៩-១១-៩៨ "

៥- ចងចាំជាកិច្ច នូវព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យជាតិដ៏ឧត្តុង្គឧត្តមរបស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ។

៦- ជយោ ! លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅព្រះរាជាណាចក្រកម្ពុជា

៧- ជយោ ! សន្តិភាព និងការបង្រួបបង្រួមជាតិ

៨- ជយោ ! ព្រះរាជាណាចក្រកម្ពុជា

៩- ជាតិ សាសនា ព្រះមហាក្សត្រ

១០- អបអរសាទរ ទិវាបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក